# ទស្សនៈកូនខ្មែរម្នាក់

( ជ្រុងមួយនៃនយោបាយស្រុកខ្មែរបច្ចុប្បន្ន ៨/១២/២០១៣ )

នៅស្រុកខ្មែរគ្មានទេគណៈបក្សនយោបាយបាយ ហើយរិតតែគ្មានទៀត គណៈបក្សនយោបាយដែលបំរើប្រយោជន៍ប្រជាជាតិខ្មែរ មានតែពួកបំផ្លាញជាតិកញ្ជះបរទេសឬពួកនិកាយនយោបាយៈ ពួកហៃអើនិងពួកផ្កាប់មុខនិយម គ្មានគិតហេតុផលអ្វីទាំងអស់ ហើយទោះយកហេតុផលមកនិយាយ ដូចនិយាយជាមួយពួកក្រៅភពឬក៏ត្រូវពួកនេះប្រមាថនិងលាពពណ៌ទាំងកំពេលបួនជ្រុង ។

បច្ចុប្បន្នមានតែទស្សនៈនិកាយនយោបាយតែពីរគត់សម្រាប់ស្រុកខ្មែរ គឺពួកនិកាយគណៈបក្សប្រជាជនកម្ពុជាបង្កើតដោយយួន និងពួកនិកាយគណៈបក្សសង្គ្រោះជាតិសម្ពន្ធ័ជាមួយក្រុមដែលបង្កើតដោយយួនតាមរយៈ ប៉ែនសុវណ្ណ មូនិកនិងស៊ីហនុ សម្រាប់ធ្វើនយោបាយកំដរនិងទ្រទ្រង់ពួកនិកាយយួន ក្រៅពីបក្សពីរនេះ គ្មានក្រុមឬទស្សនៈទីបីណាដែលអាចកើតមានបានទេ ហើយបើយើងមិនគិតដូចពួកនេះ មិនយល់ដូចពួកនេះ មិននិយាយដូចពួកនេះឬមិនចូលជាមួយពួកនេះ ដោយយើងមិនអាចចូលរួមក្នុងគំនិតនិងអំពើក្បត់របស់ពួកគេបាន ឬក៏ហ៊ានលើកយកអំពើក្បត់និងបំផ្លេចបំផ្លាញជាតិរបស់ពួកនេះមកលាតត្រដាង នឹងត្រូវពួកនេះលាបពណ៌ឬប្រមាថថា យួនឬបំរើយួន ឬចារជនយួនឬពួកស៊ីភីភី។ល។ ជាពិសេសពួកនិកាយសម-រង្ស៊ីឬសង្គ្រោះជាតិតែម្តង ។

លោកសម-រង្ស៊ី, លោកកឹម-សុខា ធ្វើនយោបាយនិងចលនាសង្គមជិតម្ភៃឆ្នាំម្នាក់ៗហើយ តើបានទប់ស្កាត់អ្វីខ្លះនៅស្រុកខ្មែរ? តើបានចំណេញអ្វីខ្លះដល់ប្រជាជាតិខ្មែរ? ឃើញតែចំណេញដល់ចិន ដល់យួន និងពួកឈ្លើងសង្គមដ៏ទៃទៀត ឯខ្មែរវិញ ខាតគ្រប់យ៉ាងៈ យួន ចិន ចូលពេញស្រុក បាត់បង់ទឹកដី សិទ្ធិសេរីភាព ពូជសាសន៍ ធនធាន សេដ្ឋកិច្ច រស់នៅក្នុងភាពទីទល់ក្រលំបាកតោកយាក ត្រូវពួកបរទេសជិះជាន់គាបសង្កត់និងប្រមាថមាក់ងាយ ហើយនៅអនាគតដ៏ខ្លីខាងមុខនឹងត្រូវរលាយបាត់ពូជសាសន៍តែម្តង ។ អ្វីដែលយើងមើលឃើញយ៉ាងជាក់ច្បាស់ គឺសម-រង្ស៊ីឬគណៈបក្ស សម-រង្ស៊ីហាក់ត្រូវបានពួកយួនឬសម្ពន្ធ័យួនប្រើប្រាស់សម្រាប់គ្រប់គ្រងកម្លាំងនិងធនធានប្រឆាំងនឹងចរន្តចិនយួន យកទៅប្រើខុសទិសដៅឬផ្អាប់ទុកចោល ដើម្បីអោយពួកបរទេសឈ្លានពានមានពេលគ្រប់គ្រាន់សម្រាប់សម្រេចផែនការណ៍លេបទឹកដីនិងបំបាត់ពូជសាសន៍ខ្មែរដូចដែលយើងឃើញបច្ចុប្បន្ន ជាពិសេសពួកវាទប់ស្កាត់ស្ទាក់ផ្លូវកុំអោយខ្មែរឯទៀតយកធនធាន និង កម្លាំងអ្នកជាតិនិយមទៅប្រើប្រាស់សម្រាប់ប្រយោជន៍ខ្មែរប្រឆាំងនឹងពួកផ្តាច់ការនិងពួកអាណានិគមន៏ចិនយួន ។

រឿងដែលធ្វើខុសកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីស២៣តុលា មិនមែនតែយួនឬពួកនិកាយយួនតែឯងទេ គឺគណៈបក្សសង្គ្រោះជាតិនិងលោកសម-រង្ស៊ីខ្លួនឯងបានរំលោភបំពានម្តងហើយម្តងទៀត ដោយបានចូលរួមបោះឆ្នោតក្នុងលក្ខខណ្ឌមួយដែលប្រឆាំងទាំងស្រុង នឹងស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីស២៣តុលា ដែលធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រយោជន៏និងវាសនាអនាគតប្រជាជាតិខ្មែរ និងពលរដ្ឋខ្មែរ ។ រឿងរ៉ាវទាំងនេះ ជាសត្យានុមត័ដែលមិនអាចប្រកែកបានហើយដែលលោក សម-រង្ស៊ី និងបក្សពួកត្រូវតែទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្រ្ត ។

ក្នុងទស្សនៈនិស្សយ័ដ៏សត្យានុមត័និងប្រាកដនិយមមួយ ពួកអ្នកនយោបាយខ្មែរបច្ចុប្បន្នគ្មានក្រុមណាមួយឯករាជទេ ពួកគណបក្សប្រជាជនកម្ពុជាក៏ដូចពួកសង្គ្រោះជាតិ ក្រុមទាំងពីរនេះមិនដែលមានឆន្ទៈឬគោលនយោបាយបំរើខ្មែរទាល់តែសោះក្រៅពីបំរើម្ចាស់របស់ពួកគេនិងប្រើវោហាសាស្រ្តបោកប្រាស់ ពួកផ្កាប់មុខ ៖ ហ៊ុន-សែន ជាប់ជាមួយចិនខ្លាំងជាងយួន(ពេលបច្ចុប្បន្ន) លោកសម-រង្ស៊ី ជាប់ជាមួយចិន តាមសម្ពន័ចិនយួន(ពួកស្តេចនិងពួកសក្តិភូមិ) ឯលោក កឹម-សុខា ជាប់ជាមួយក្រុមយួនតាមរយៈប៉ែន-សុវណ្ណនិងបរិវា ឯខ្មែរគឺបាតដៃទទេស្អាត ហើយត្រូវពួកក្បត់ជាតិទាំងនេះ ប្រើវោហាសាស្រ្តបោកប្រាស់យកលុយកាក់ ពេលវេលា និងធនធានដ៏ទៃទៀតយកទៅបំរើផលប្រយោជន៍យួននិងបំផ្លាញជាតិខ្មែរដោយប្រយោលឬដោយផ្ទាល់ ។ ទាំងនេះបញ្ជាក់ហេតុផល ហេតុអ្វីយួនសម្លាប់បំបាត់ពូជខ្មែរអ្នកចេះដឹងនិងស្នេហាជាតិ ហើយលោកសម-រង្ស៊ី សោតក៏មិនខុសពីយួនដែរ ស្អប់ខ្ពើមនិងច្រានចោលអ្នកចេះដឹងនិងស្នេហាជាតិខ្មែរ ហើយប្រមូលតែពួកក្បត់ជាតិនិងពួកឡេមឡឹមដ៏ទៃទៀតនៅជុំវិញខ្លួន ។ ទស្សនៈកូនខ្មែរ